# ព្រះរាជក្រឹត្យ

នស/រកត/០៣២៣/៥២០

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាតុលាការយុត្តិធម៌កម្ពុជា

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ព្រះរាជក្រឹត្យនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃ **បណ្ឌិត្យសភាបណ្តុះបណ្តាលយុត្តិធម៌កម្ពុជា** សរសេរជាអក្សរកាត់ថា "**ប.ភ.យ.ក.**" ដែលជាគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ ក្នុងគោលបំណងធានា និងលើកកម្ពស់សមត្ថភាព គុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការ វិជ្ជាជីវៈច្បាប់ និងជំនាញផ្សេងទៀតក្នុងវិស័យច្បាប់ និងយុត្តិធម៌ ព្រមទាំងពង្រឹងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជា។

រូបសញ្ញា **ប.ភ.យ.ក.** មានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា២ .-**

ប.ភ.យ.ក. មានមុខងារ និងភារកិច្ច ដូចតទៅ៖

- រៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម សិស្សព្រះរាជអាជ្ញា សិស្សអាជ្ញាសាលា សិស្សក្រឡាបញ្ជី សិស្សសារការី ព្រមទាំងសិស្សវិជ្ជាជីវៈតុលាការនិងវិជ្ជាជីវៈច្បាប់ផ្សេងទៀត
- រៀបចំការបណ្តុះបណ្តាលដំបូងដល់សិស្សចៅក្រម សិស្សព្រះរាជអាជ្ញា សិស្សអាជ្ញាសាលា សិស្សក្រឡាបញ្ជី សិស្សសារការី ព្រមទាំងសិស្សវិជ្ជាជីវៈតុលាការនិងវិជ្ជាជីវៈច្បាប់ផ្សេងទៀត
- រៀបចំការបណ្តុះបណ្តាលបន្ត តាមរយៈវគ្គសុក្រឹតការ និងវគ្គវិក្រឹតការ ដល់ចៅក្រម ព្រះរាជអាជ្ញា អាជ្ញាសាលា ក្រឡាបញ្ជី សារការី ព្រមទាំងអ្នកប្រកបវិជ្ជាជីវៈតុលាការនិងវិជ្ជាជីវៈច្បាប់ផ្សេងទៀត
- រៀបចំការបណ្តុះបណ្តាលពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌ដល់មន្ត្រីរាជការនៃក្រសួងយុត្តិធម៌ មន្ត្រីរដ្ឋបាលតុលាការនៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងមន្ត្រីអនុវត្តច្បាប់នៅតាមក្រសួង ស្ថាប័ននានា
- រៀបចំវគ្គសិក្សាត្រៀមសម្រាប់ការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម សិស្សព្រះរាជអាជ្ញា សិស្សអាជ្ញាសាលា សិស្សក្រឡាបញ្ជី សិស្សសារការី ព្រមទាំងសិស្សវិជ្ជាជីវៈតុលាការនិងវិជ្ជាជីវៈច្បាប់ផ្សេងទៀត
- រៀបចំការបណ្តុះបណ្តាលជំនាញផ្នែកច្បាប់ និងយុត្តិធម៌ កម្រិតឧត្តមសិក្សា និងកម្រិតក្រោយឧត្តមសិក្សា និងជំនាញពាក់ព័ន្ធផ្សេងទៀត
- រៀបចំការបណ្តុះបណ្តាលជំនាញរយៈពេលខ្លីផ្នែកច្បាប់ និងយុត្តិធម៌ ព្រមទាំងសន្និសីទ សិក្ខាសាលា និងកម្មវិធីចែករំលែកចំណេះដឹងនិងបទពិសោធន៍ពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌
- រៀបចំជ្រើសរើស និងបណ្តុះបណ្តាលសាស្ត្រាចារ្យ និងគ្រូបង្រៀន ដើម្បីធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការ វិជ្ជាជីវៈច្បាប់ និងជំនាញផ្សេងទៀតក្នុងវិស័យច្បាប់ និងយុត្តិធម៌នៅ **ប.ភ.យ.ក.**
- រៀបចំការផ្តល់គោរមងារកិត្តិយស ឋានៈ ងារ និងគ្រឿងឥស្សរិយយសដល់វរជន និងឥស្សរជនជាតិ និងបរទេស ដែលជាសាស្ត្រាចារ្យ និងគ្រូបង្រៀននៃ **ប.ភ.យ.ក.** ឬវរជន និងឥស្សរជនផ្សេងទៀត ដែលបំពេញការងារក្នុងវិស័យយុត្តិធម៌

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- សហការរៀបចំ និងអនុវត្តការងារសិក្សាស្រាវជ្រាវក្នុងក្របខ័ណ្ឌការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ធ្វើការសិក្សាស្រាវជ្រាវ ចងក្រង បោះពុម្ព ផ្សព្វផ្សាយ និងតម្កល់ស្នាដៃផ្សេងៗ ពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌ ព្រមទាំងវិស័យពាក់ព័ន្ធផ្សេងទៀត
- ពិនិត្យ និងវាយតម្លៃស្នាដៃស្រាវជ្រាវបែបវិទ្យាសាស្ត្រពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌ ដើម្បីទទួលបានការទទួលស្គាល់ពី **ប.ភ.យ.ក.**
- ធ្វើទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ដើម្បីធានាគុណភាព និងប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលរបស់ **ប.ភ.យ.ក.**
- អនុវត្តមុខងារ និងភារកិច្ចផ្សេងទៀតដែលក្រសួងយុត្តិធម៌ប្រគល់ឱ្យ សំដៅលើកកម្ពស់សមត្ថភាព គុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការ វិជ្ជាជីវៈច្បាប់ និងជំនាញផ្សេងទៀតក្នុងវិស័យច្បាប់ និងយុត្តិធម៌ ព្រមទាំងពង្រឹងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ការដឹកនាំ និងការគ្រប់គ្រង

**មាត្រា៣ ._**

**ប.ភ.យ.ក.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ដែលមានសិទ្ធិអំណាចទូទៅ ដើម្បីចាត់ចែងការងារក្នុងក្របខ័ណ្ឌដែលត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

ក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** មានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១ រូប | អនុប្រធាន |
| - ប្រធាន **ប.ភ.យ.ក.** | | អនុប្រធានប្រចាំការ |
| - តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | ១ រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | សមាជិក |
| - តំណាងក្រសួងមុខងារសាធារណៈ | ១ រូប | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| - ឥស្សរជនដែលមានសញ្ញាបត្រថ្នាក់បណ្ឌិតផ្នែកច្បាប់ ឬដែលមានបទពិសោធន៍ក្នុងវិស័យច្បាប់ យុត្តិធម៌ រដ្ឋបាល សេដ្ឋកិច្ច ឬសង្គមសាស្ត្រ យ៉ាងតិច ១០ (ដប់)ឆ្នាំ | ៣ រូប | សមាជិក |
| - នាយកសាលាភូមិន្ទនីមួយៗ នាយកសាលាច្បាប់ អគ្គលេខាធិការ និងប្រធានអង្គភាពផ្សេងទៀតចំណុះ **ប.ភ.យ.ក.** ដែលត្រូវបង្កើតឡើងស្របតាមព្រះរាជក្រឹត្យនេះ | | សមាជិក។ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

សមាសភាពក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។ សមាជិកក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** មានអាណត្តិ ៥ (ប្រាំ)ឆ្នាំ។ នៅពេលចប់អាណត្តិ សមាជិកក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** អាចត្រូវបានតែងតាំងបន្តសម្រាប់អាណត្តិថ្មីបាន។

សមាសភាពក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ទទួលបានប្រាក់លាភការស្របតាមការកំណត់ក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។

**មាត្រា៤.-**

ក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** មានភារកិច្ច ដូចតទៅ៖

- ពិនិត្យ និងអនុម័តផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ ផែនការសកម្មភាព គម្រោងថវិកានិងគម្រោងលទ្ធកម្មប្រចាំឆ្នាំរបស់ **ប.ភ.យ.ក.**
- ពិនិត្យ និងអនុម័តផែនការនិងកម្មវិធីបណ្តុះបណ្តាល និងផែនការស្រាវជ្រាវរបស់ **ប.ភ.យ.ក.**
- ពិនិត្យ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ **ប.ភ.យ.ក.** ព្រមទាំងសំណើផ្សេងៗរបស់ប្រធាន **ប.ភ.យ.ក.** ដែលទាក់ទងនឹងដំណើរការប្រព្រឹត្តទៅ និងការអនុវត្តមុខងារ និងភារកិច្ចរបស់ **ប.ភ.យ.ក.**
- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំរបស់ **ប.ភ.យ.ក.**
- ពិនិត្យ និងអនុម័តលើការរៀបចំ និងការប្រព្រឹត្តទៅនៃរចនាសម្ព័ន្ធបន្ថែមរបស់អង្គភាពចំណុះ **ប.ភ.យ.ក.**
- ពិនិត្យ និងអនុម័តលើសំណើរបស់ប្រធាន **ប.ភ.យ.ក.** ក្នុងការកំណត់ក្របខ័ណ្ឌ និងចំនួនបុគ្គលិកប្រចាំឆ្នាំរបស់ **ប.ភ.យ.ក.**
- ពិនិត្យ និងអនុម័តលើសំណើរបស់ប្រធាន **ប.ភ.យ.ក.** ពាក់ព័ន្ធនឹងការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗដល់ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ គ្រូបង្រៀន និងបុគ្គលិកនៃ **ប.ភ.យ.ក.**
- ពិនិត្យ និងវាយតម្លៃបេក្ខភាពសម្រាប់ស្នើសុំផ្តល់គោរមងារកិត្តិយស ឋានៈ និងងារ ព្រមទាំងគ្រឿងឥស្សរិយយសផ្សេងៗ
- ពិនិត្យ និងសម្រេចលើគោលការណ៍នៃការផ្តល់សញ្ញាបត្រ វិញ្ញាបនបត្រ បណ្ណសរសើរ និងពានរង្វាន់ផ្សេងៗ ព្រមទាំងការផ្តល់ការទទួលស្គាល់ទេពកោសល្យក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រង និងសមិទ្ធកម្មរបស់ **ប.ភ.យ.ក.** ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំនព្វមាស និងប្រចាំឆ្នាំ
- បំពេញកិច្ចការផ្សេងទៀតដែលចាំបាច់ ដើម្បីសម្រេចមុខងារ និងភារកិច្ចរបស់ **ប.ភ.យ.ក.**។

**មាត្រា៥.-**

**ប.ភ.យ.ក.** ត្រូវគ្រប់គ្រងដោយប្រធាន ១ (មួយ)រូប និងអមដោយអនុប្រធានមួយចំនួន ដែលត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។

**មាត្រា៦ .-**

ប្រធាន **ប.ភ.យ.ក.** មានភារកិច្ច ដូចតទៅ៖

- ជាតំណាងរបស់ **ប.ភ.យ.ក.** ក្នុងទំនាក់ទំនងជាមួយបុគ្គលឯកជន ឬបុគ្គលសាធារណៈនានា
- ដឹកនាំ និងគ្រប់គ្រងប្រតិបត្តិការរបស់ **ប.ភ.យ.ក.** ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ដឹកនាំអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលអនុម័ត ដោយក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**
- ដឹកនាំ និងសម្របសម្រួលលើការលើកគម្រោងថវិកានិងគម្រោងលទ្ធកម្មប្រចាំឆ្នាំរបស់ **ប.ភ.យ.ក.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ពិនិត្យ និងអនុម័ត
- ដឹកនាំ និងសម្របសម្រួលលើការរៀបចំផែនការអភិវឌ្ឍន៍ ផែនការបណ្តុះបណ្តាល ផែនការសកម្មភាព និងផែនការផ្សេងទៀតរបស់ **ប.ភ.យ.ក.** ជូនក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ពិនិត្យ និងអនុម័ត
- ដឹកនាំការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់ដោយ **ប.ភ.យ.ក.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ពិនិត្យ និងអនុម័ត
- លើកសំណើរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការកំណត់មុខងារ ក្របខ័ណ្ឌ និងចំនួនបុគ្គលិករបស់ **ប.ភ.យ.ក.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ពិនិត្យ និងអនុម័ត
- លើកសំណើផ្តល់គោរមងារកិត្តិយស ឋានៈ ងារ និងគ្រឿងឥស្សរិយយសដល់វរជន និងឥស្សរជនជាតិ និងបរទេស ដែលជាសាស្ត្រាចារ្យ និងគ្រូបង្រៀននៃ **ប.ភ.យ.ក.** ឬវរជន និងឥស្សរជនផ្សេងទៀត ដែលបំពេញការងារក្នុងវិស័យយុត្តិធម៌ ជូនក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ពិនិត្យ និងអនុម័ត
- លើកសំណើសុំលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗដល់ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ គ្រូបង្រៀន និងបុគ្គលិកនៃ **ប.ភ.យ.ក.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ពិនិត្យ និងអនុម័ត
- ដឹកនាំ និងសម្របសម្រួលការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ដឹកនាំរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ពិនិត្យ និងអនុម័ត
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ប្រគល់ឱ្យ។

**មាត្រា៧ .-**

**ប.ភ.យ.ក.** មានក្រុមប្រឹក្សាវិទ្យាសាស្ត្រ និងគរុកោសល្យមួយ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| - ប្រធាន **ប.ភ.យ.ក.** | | ប្រធាន |
| - តំណាងក្រសួងយុត្តិធម៌ | ១ រូប | សមាជិក |
| នាយកសាលាភូមិន្ទនីមួយៗ នាយកសាលាច្បាប់ និងប្រធានអង្គភាពផ្សេងទៀតចំណុះ **ប.ភ.យ.ក.** ដែលត្រូវបង្កើតឡើងស្របតាមព្រះរាជក្រឹត្យនេះ | | សមាជិក |

- សាស្ត្រាចារ្យ ឬឥស្សរជនដែលមានសញ្ញាបត្រថ្នាក់បណ្ឌិតផ្នែកច្បាប់ ឬដែលមានបទពិសោធន៍ក្នុងវិស័យច្បាប់ យុត្តិធម៌ រដ្ឋបាល សេដ្ឋកិច្ច ឬសង្គមសាស្ត្រ យ៉ាងតិច ១០ (ដប់) ឆ្នាំ ៥ រូប សមាជិក។

សមាសភាពក្រុមប្រឹក្សាវិទ្យាសាស្ត្រ និងគរុកោសល្យនៃ **ប.ភ.យ.ក.** ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។

សមាសភាពក្រុមប្រឹក្សាវិទ្យាសាស្ត្រ និងគរុកោសល្យនៃ **ប.ភ.យ.ក.** ទទួលបានលាភការ និងប្រាក់ឧបត្ថម្ភផ្សេងទៀត ស្របតាមការកំណត់ក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។ សមាសភាពក្រុមប្រឹក្សាវិទ្យាសាស្ត្រ និងគរុកោសល្យនៃ **ប.ភ.យ.ក.** ដែលជាសមាសភាពក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** អាចទទួលប្រាក់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងទៀតតែមួយប៉ុណ្ណោះដែលមានកម្រិតខ្ពស់ជាងគេក្នុងចំណោមប្រាក់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងទៀត សម្រាប់មុខងារទាំងពីរនេះ។

**មាត្រា៨ .-**

ក្រុមប្រឹក្សាវិទ្យាសាស្ត្រ និងគរុកោសល្យនៃ **ប.ភ.យ.ក.** មានភារកិច្ច ដូចតទៅ៖

- ពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃលើកម្មវិធីបណ្តុះបណ្តាល កម្មវិធីសិក្សា និងការស្រាវជ្រាវរបស់ **ប.ភ.យ.ក.**
- ពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃអំពីគុណវុឌ្ឍិបេក្ខភាពដែលត្រូវស្នើសុំឋានៈជាសាស្ត្រាចារ្យនៃ **ប.ភ.យ.ក.**
- កំណត់លក្ខណៈវិនិច្ឆ័យ និងលក្ខណសម្បត្តិសម្រាប់ការជ្រើសរើសសាស្ត្រាចារ្យ និងគ្រូបង្រៀន ដើម្បីធានានូវគុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ
- ផ្តល់យោបល់លើគោលនយោបាយ និងយុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវរបស់ **ប.ភ.យ.ក.**
- ពិនិត្យ និងវាយតម្លៃស្នាដៃស្រាវជ្រាវបែបវិទ្យាសាស្ត្រពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌ ដើម្បីទទួលបានការទទួលស្គាល់ពី **ប.ភ.យ.ក.**
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ប្រគល់ឱ្យ។

**មាត្រា៩ .-**

**ប.ភ.យ.ក.** អាចមានទីប្រឹក្សាមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

## ជំពូកទី៣
## រចនាសម្ព័ន្ធនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

**មាត្រា១០ .-**

**ប.ភ.យ.ក.** មានរចនាសម្ព័ន្ធ ដូចខាងក្រោម៖

- សាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា
- សាលាភូមិន្ទអាជ្ញាសាលា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- សាលាភូមិន្ទក្រឡាបញ្ជី
- សាលាភូមិន្ទសារការី
- សាលាច្បាប់
- អគ្គលេខាធិការដ្ឋាននៃ **ប.ភ.យ.ក.**។

រចនាសម្ព័ន្ធចំណុះ **ប.ភ.យ.ក.** មានកម្រិតស្មើអគ្គនាយកដ្ឋាន។

**ប.ភ.យ.ក.** និងរចនាសម្ព័ន្ធចំណុះ **ប.ភ.យ.ក.** នីមួយៗ មានត្រាសម្រាប់អនុវត្តភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្នែករដ្ឋបាលដោយ **ប.ភ.យ.ក.** និងផ្នែកបច្ចេកទេសដោយផ្ទាល់ពីក្រុមប្រឹក្សាគណៈមេធាវី។ ផ្នែករដ្ឋបាលនេះ រួមមានការគាំពារលើអគារ បន្ទប់សិក្សា សម្ភារបរិក្ខារសិក្សា សន្តិសុខ និងសណ្តាប់ធ្នាប់ នៅក្នុងបរិវេណនៃ **ប.ភ.យ.ក.**។

ក្នុងករណីចាំបាច់ រចនាសម្ព័ន្ធផ្សេងទៀតចំណុះ **ប.ភ.យ.ក.** អាចត្រូវបានបង្កើតឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។

អង្គការលេខនៃ **ប.ភ.យ.ក.** មានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា១១ .-**

សាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា មានមុខងារ និងភារកិច្ចជ្រើសរើស និងបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងដល់សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ព្រមទាំងរៀបចំការបណ្តុះបណ្តាលបន្ត តាមរយៈវគ្គសុក្រឹតការ និងវគ្គវិក្រឹតការ ដល់ចៅក្រម និងព្រះរាជអាជ្ញាដែលកំពុងបំពេញការងារយកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១២ .-**

សាលាភូមិន្ទអាជ្ញាសាលា មានមុខងារ និងភារកិច្ចជ្រើសរើស និងបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងដល់សិស្សអាជ្ញាសាលា ព្រមទាំងរៀបចំការបណ្តុះបណ្តាលបន្ត តាមរយៈវគ្គសុក្រឹតការ និងវគ្គវិក្រឹតការ ដល់អាជ្ញាសាលាដែលកំពុងបំពេញការីយកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៣ .-**

សាលាភូមិន្ទក្រឡាបញ្ជី មានមុខងារ និងភារកិច្ចជ្រើសរើស និងបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងដល់សិស្សក្រឡាបញ្ជី ព្រមទាំងរៀបចំការបណ្តុះបណ្តាលបន្ត តាមរយៈវគ្គសុក្រឹតការ និងវគ្គវិក្រឹតការ ដល់ក្រឡាបញ្ជីដែលកំពុងបំពេញការីយកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៤ .-**

សាលាភូមិន្ទសារការី មានមុខងារ និងភារកិច្ចជ្រើសរើស និងបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងដល់សិស្សសារការី ព្រមទាំងរៀបចំការបណ្តុះបណ្តាលបន្ត តាមរយៈវគ្គសុក្រឹតការ និងវគ្គវិក្រឹតការ ដល់សារការីដែលកំពុងបំពេញការីយកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៥ .-**

សាលាច្បាប់ មានមុខងារ និងភារកិច្ចជាចម្បង ដូចតទៅ៖

- រៀបចំការបណ្តុះបណ្តាលពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌ ដល់មន្ត្រីរដ្ឋបាលតុលាការនៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- រៀបចំការបណ្តុះបណ្តាលពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌ ដល់មន្ត្រីរាជការដែលកំពុងបម្រើការងារនៅក្រសួងយុត្តិធម៌ និងមន្ត្រីអនុវត្តច្បាប់នៅតាមក្រសួង ស្ថាប័ននានា
- រៀបចំការបណ្តុះបណ្តាលជំនាញផ្នែកច្បាប់ និងយុត្តិធម៌ កម្រិតឧត្តមសិក្សា កម្រិតក្រោយឧត្តមសិក្សា និងជំនាញពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់
- រៀបចំវគ្គសិក្សាត្រៀមសម្រាប់ការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម សិស្សព្រះរាជអាជ្ញា សិស្សអាជ្ញាសាលា សិស្សក្រឡាបញ្ជី សិស្សសារការី និងសិស្សវិជ្ជាជីវៈតុលាការនិងវិជ្ជាជីវៈច្បាប់ផ្សេងទៀត
- រៀបចំការបណ្តុះបណ្តាលជំនាញរយៈពេលខ្លីផ្នែកច្បាប់ និងយុត្តិធម៌ ព្រមទាំងសន្និសីទ សិក្ខាសាលា និងកម្មវិធីចែករំលែកចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌
- ធ្វើការសិក្សាស្រាវជ្រាវ ចងក្រង បោះពុម្ព ផ្សព្វផ្សាយ និងតម្កល់ស្នាដៃផ្សេងៗ ពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌ ព្រមទាំងវិស័យពាក់ព័ន្ធផ្សេងទៀត
- ធ្វើទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ លើការបណ្តុះបណ្តាល និងការស្រាវជ្រាវក្នុងវិស័យច្បាប់ និងយុត្តិធម៌
- មុខងារ និងភារកិច្ចបន្ថែមផ្សេងទៀតរបស់សាលាច្បាប់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៦ .-**

អគ្គលេខាធិការដ្ឋាននៃ **ប.ភ.យ.ក.** ទទួលបន្ទុកកិច្ចការរដ្ឋបាលទូទៅ ទំនាក់ទំនងសាធារណៈ ការងារបូកសរុប និងការសម្របសម្រួលការងារហិរញ្ញវត្ថុ ដើម្បីគាំទ្រកិច្ចដំណើរការរបស់ **ប.ភ.យ.ក.**។

អគ្គលេខាធិការដ្ឋាននៃ **ប.ភ.យ.ក.** ត្រូវទទួលបន្ទុកសម្របសម្រួលប្រមូលផ្តុំគម្រោងថវិកាប្រចាំឆ្នាំរបស់អង្គភាពចំណុះ **ប.ភ.យ.ក.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ពិនិត្យ និងអនុម័ត តាមរយៈប្រធាន **ប.ភ.យ.ក.** ព្រមទាំងការផ្តល់យោបល់លើការរៀបចំ និងការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំរបស់អង្គភាពចំណុះ **ប.ភ.យ.ក.**។

**មាត្រា១៧ .-**

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី មានមុខងារ និងភារកិច្ច ស្របតាមការកំណត់របស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

**មាត្រា១៨ .-**

សាលាភូមិន្ទនីមួយៗ និងសាលាច្បាប់ ត្រូវគ្រប់គ្រងដោយនាយក ១ (មួយ)រូប និងអមដោយនាយករងមួយចំនួន តាមការចាំបាច់។

អគ្គលេខាធិការដ្ឋាននៃ **ប.ភ.យ.ក.** ដឹកនាំដោយអគ្គលេខាធិការ ១ (មួយ)រូប និងអមដោយអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់។

នាយកសាលាភូមិន្ទនីមួយៗ នាយកសាលាច្បាប់ និងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ **ប.ភ.យ.ក.** ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។

នាយករងសាលាភូមិន្ទនីមួយៗ នាយករងសាលាច្បាប់ និងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃ **ប.ភ.យ.ក.** ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។

**មាត្រា១៩ .-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាភូមិន្ទនីមួយៗ សាលាច្បាប់ និងអគ្គលេខាធិការដ្ឋាននៃ **ប.ភ.យ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៤
## ការជ្រើសរើសសិស្ស និងការបណ្តុះបណ្តាល

**មាត្រា២០ .-**

ការជ្រើសរើសសិស្សចៅក្រម សិស្សព្រះរាជអាជ្ញា សិស្សអាជ្ញាសាលា សិស្សក្រឡាបញ្ជី និងសិស្សសារការី នៃ **ប.ភ.យ.ក.** ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែង ឬតាមវិធីផ្សេងទៀតដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ត្រូវបានជ្រើសរើសរួមគ្នា និងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងរួមគ្នា ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ការកំណត់បែងចែកដាច់ពីគ្នារវាងសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា អាចធ្វើឡើងនៅដំណាក់កាលដំបូងនៃការជ្រើសរើស ឬនៅពេលនៃការបែងចែកឯកទេសកម្មក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូង។ ក្នុងករណីដែលសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញាត្រូវបានបែងចែកដាច់ពីគ្នាតាំងពីដំណាក់កាលដំបូងនៃការជ្រើសរើស សិស្សចៅក្រមអាចផ្លាស់ប្តូរទៅជាសិស្សព្រះរាជអាជ្ញា ហើយសិស្សព្រះរាជអាជ្ញាក៏អាចផ្លាស់ប្តូរទៅជាសិស្សចៅក្រមវិញបានដែរ ដោយយោងតាមតម្រូវការចាំបាច់នៃវិស័យយុត្តិធម៌ និងការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងប្រជែងជ្រើសរើសសិស្ស និងការបណ្តុះបណ្តាលនៅ **ប.ភ.យ.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្របតាមច្បាប់ជាធរមាន។

**មាត្រា២១ .-**

រាជរដ្ឋាភិបាល អាចជ្រើសរើសមន្ត្រីរាជការនៃក្រសួងយុត្តិធម៌ ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងដែលមានគុណសម្បត្តិការងារខ្ពស់ចំនួន ៥ (ប្រាំ)រូប ឱ្យចូលរៀនក្នុងជំនាន់នីមួយៗ នៅសាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា សាលាភូមិន្ទអាជ្ញាសាលា សាលាភូមិន្ទក្រឡាបញ្ជី និងសាលាភូមិន្ទសារការី ដោយពុំចាំបាច់ឆ្លងកាត់ការប្រឡងប្រជែងជ្រើសរើស តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។

## ជំពូកទី៥
## ឋានៈ និងងារ នៃគ្រូបង្រៀន និងគោរមងារកិត្តិយស នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

**មាត្រា២២ .-**

គ្រូបង្រៀននៃ **ប.ភ.យ.ក.** រួមមាន គ្រូបង្រៀនប្រចាំនៅ **ប.ភ.យ.ក.** និងគ្រូបង្រៀនដែលត្រូវបានអញ្ជើញដើម្បីផ្តល់បាឋកថា ធ្វើបទឧទ្ទេសនាម ឬធ្វើបទអន្តរាគមន៍នានាតាមការចាំបាច់នៅ **ប.ភ.យ.ក.**។

គ្រូបង្រៀននៃ **ប.ភ.យ.ក.** អាចត្រូវបានជ្រើសរើសពីក្នុងចំណោមឥស្សរជន សាស្ត្រាចារ្យ អ្នកស្រាវជ្រាវជំនាញខ្ពស់ ឬបុគ្គលដែលមានស្នាដៃ និងបទពិសោធន៍ការងារខ្ពស់។

គ្រូបង្រៀននៃ **ប.ភ.យ.ក.** អាចត្រូវបានផ្តល់ឋានៈជាសាស្ត្រាចារ្យនៃ **ប.ភ.យ.ក.**។

គុណវុឌ្ឍិសម្រាប់ការពិនិត្យ និងវាយតម្លៃក្នុងការផ្តល់ឋានៈជាសាស្ត្រាចារ្យនៃ **ប.ភ.យ.ក.** មានដូចតទៅ៖

- មានសញ្ញាបត្រកម្រិតឧត្តមសិក្សា ឬក្រោយឧត្តមសិក្សា ឬសញ្ញាបត្រសមមូល
- បាននិពន្ធសៀវភៅសិក្សាស្រាវជ្រាវ ឬអត្ថបទស្រាវជ្រាវ ដែលមានលក្ខណៈវិទ្យាសាស្ត្រ និងគរុកោសល្យ និងត្រូវបានផ្សព្វផ្សាយជាសាធារណៈយ៉ាងតិចចំនួន ៣ (បី)
- បានបង្រៀននៅ **ប.ភ.យ.ក.** បានយ៉ាងតិច ៥ (ប្រាំ)ឆ្នាំ លើកលែងតែ គ្រូបង្រៀនប្រចាំនៅ **ប.ភ.យ.ក.** និង
- មានបទពិសោធន៍ការងារក្នុងជំនាញរបស់ខ្លួនយ៉ាងតិច ១០ (ដប់)ឆ្នាំ ឬយ៉ាងតិច ៥ (ប្រាំ)ឆ្នាំ ប្រសិនបើមានសញ្ញាបត្រថ្នាក់បណ្ឌិត។

ក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** ពិនិត្យ និងវាយតម្លៃលើគុណវុឌ្ឍិសម្រាប់ការស្នើសុំផ្តល់ឋានៈជាសាស្ត្រាចារ្យនៃ **ប.ភ.យ.ក.** ដល់គ្រូបង្រៀននៃ **ប.ភ.យ.ក.** តាមសំណើរបស់ប្រធាន **ប.ភ.យ.ក.** តាមសេចក្តីស្នើសុំពីក្រុមប្រឹក្សាវិទ្យាសាស្ត្រ និងគរុកោសល្យនៃ **ប.ភ.យ.ក.**។

ការផ្តល់ឋានៈជាសាស្ត្រាចារ្យនៃ **ប.ភ.យ.ក.** ធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។

**មាត្រា២៣ ._**

គ្រូបង្រៀននៃ **ប.ភ.យ.ក.** ដែលទទួលបានឋានៈជាសាស្ត្រាចារ្យនៃ **ប.ភ.យ.ក.** ត្រូវទទួលបានងារជា **ឯកឧត្តម ឬលោកជំទាវ** ដោយពេញច្បាប់។ សាស្ត្រាចារ្យនៃ **ប.ភ.យ.ក.** ទទួលបានប្រាក់ម៉ោងបង្រៀនខ្ពស់ជាងគ្រូបង្រៀនផ្សេងទៀតនៅ **ប.ភ.យ.ក.**។

**មាត្រា២៤ ._**

**ប.ភ.យ.ក.** អាចរៀបចំឱ្យមានគោរមងារកិត្តិយស សម្រាប់ផ្តល់ជូនដល់វរជន ឥស្សរជន ថៅក្រម ឬព្រះរាជអាជ្ញា ដែលមានគុណបំណាច់ និងស្នាដៃក្នុងការដឹកនាំ ការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា។

គោរមងារកិត្តិយសនៃ **ប.ភ.យ.ក.** ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។

## ជំពូកទី៦

## បុគ្គលិករបស់បណ្ឌិត្យសភាតុលាការ និងវិជ្ជាជីវៈយុត្តិធម៌កម្ពុជា

**មាត្រា២៥ ._**

បុគ្គលិករបស់ **ប.ភ.យ.ក.** រួមមាន មន្ត្រីរាជការក្របខ័ណ្ឌនៃក្រសួងយុត្តិធម៌ និងមន្ត្រីជាប់កិច្ចសន្យា។

**ប.ភ.យ.ក.** ត្រូវបានអនុញ្ញាតឱ្យជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួន ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បុគ្គលិករបស់ **ប.ភ.យ.ក.** ទទួលបានការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ស្របតាមច្បាប់ និងលិខិតបទដ្ឋាគតិយុត្តជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗពីថវិការដ្ឋជូនថ្នាក់ដឹកនាំ សាស្ត្រាចារ្យ គ្រូបង្រៀន និងបុគ្គលិករបស់ **ប.ភ.យ.ក.** ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលជាប្រធានក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.**។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី៧
## ទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

**មាត្រា២៦.-**

សាលាភូមិន្ទនីមួយៗ សាលាច្បាប់ និងអគ្គលេខាធិការដ្ឋាននៃ **ប.ភ.យ.ក.** មានថវិកាសម្រាប់គាំទ្រដំណើរការរបស់ខ្លួន ដែលមានប្រភពពីថវិការដ្ឋ និងពីប្រភពស្របច្បាប់ផ្សេងទៀតស្របតាមព្រះរាជក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ថវិកាពីប្រភពថវិការដ្ឋរបស់សាលាភូមិន្ទនីមួយៗ សាលាច្បាប់ និងអគ្គលេខាធិការដ្ឋាននៃ **ប.ភ.យ.ក.** គឺជាកញ្ចប់ថវិកាផ្ទាល់ដោយឡែកនៅក្នុងក្របខ័ណ្ឌនៃថវិកាកម្មវិធីរបស់ក្រសួងយុត្តិធម៌។

បន្ទាប់ពីទទួលបានគោលការណ៍ពីក្រុមប្រឹក្សាភិបាល **ប.ភ.យ.ក.** សាលាភូមិន្ទនីមួយៗ សាលាច្បាប់ និងអគ្គលេខាធិការដ្ឋាននៃ **ប.ភ.យ.ក.** មានសិទ្ធិទទួល គ្រប់គ្រង និងចាត់ចែងធនធានដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ចំណូលដែលកើតចេញពីការធ្វើសកម្មភាព ឬការផ្តល់សេវាផ្សេងៗរបស់ខ្លួន និងអំណោយរបស់រដ្ឋ អំណោយឬអច្ច័យទានរបស់ឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងចំណូលពីប្រភពស្របច្បាប់ផ្សេងទៀត សម្រាប់ចំណាយលើការបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ សេវារដ្ឋបាលនិងបុគ្គលិក និងការផ្តល់លាភការ ឬប្រាក់ឧបត្ថម្ភផ្សេងៗ ព្រមទាំងសម្រាប់បម្រើសេចក្តីត្រូវការក្នុងការផ្គត់ផ្គង់សម្ភារបរិក្ខារ តាមការចាំបាច់ ក្នុងគោលដៅធានាការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់ **ប.ភ.យ.ក.** ត្រូវអនុវត្តស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា២៧.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៨ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា២៨.-**

**រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ** ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ត្រូវប្តូរឈ្មោះទៅជា **បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា**។

ព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយព្រះរាជក្រឹត្យនេះ។

**មាត្រា២៩ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃសៅរ៍ ៤កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០២៣

នស.រកត.០៣២៣.៥៤៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យលេខនស/រកត/០៧២៣/៥៤០.....ចុះថ្ងៃទី២៥...ខែកក្កដា...ឆ្នាំ២០២៣
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

## រូបសញ្ញានៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

រូបសញ្ញារបស់បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា មានទម្រង់ជាពានក្រពើពណ៌មាស តំណាងឱ្យសក្តានុពល និងគុណតម្លៃដ៏ខ្ពង់ខ្ពស់ នៃការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការ ប្រកបដោយគុណភាព, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព ស្របតាមលក្ខណៈបច្ចេកទេស វិទ្យាសាស្ត្រ និងគុរុកោសល្យ ហើយត្រូវបានចែកចេញជា ៤ ផ្នែក តាមលំដាប់ពីលើចុះក្រោម និងមានអត្ថន័យ ដូចតទៅ៖

**ទី១-ផ្នែកកំពូលខាងលើ៖** មានទម្រង់ជាក្បាំងមកុដ លម្អដោយសត្វនាគមួយគូ បែរមុខចេញក្រៅ ប្រកបដោយក្បូរក្បាច់រចនាល្អឆើតឆាយតាមរចនាបទអង្គរដ៏រុងរឿង ដែលតំណាងឱ្យ៖

- អ្នកការពារយុត្តិធម៌សង្គម ប្រកបដោយថាមពលខ្លាំងក្លា, ឆន្ទៈមោះមុត និងអង់អាចក្លាហាន
- ភាពរីកចម្រើន រុងរឿងលើគ្រប់ផ្នែក ក្នុងវិស័យយុត្តិធម៌ និងតុលាការ
- ការផ្សព្វផ្សាយ ក៏ដូចជាការផ្ទេរនូវចំណេះដឹង ជំនាញច្បាប់ ដល់អ្នកវិជ្ជាជីវៈច្បាប់ និងតុលាការ
- កំពូលមកុដ កើតឡើងពីការរឹញចូលគ្នាជាធ្លុងមួយរបស់នាគមួយគូ ជាតំណាងកិច្ចសហការជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, សាលាជម្រះក្តីនានាក្នុងព្រះរាជាណាចក្រកម្ពុជា, ស្ថាប័នតុលាការអន្តរជាតិ ព្រមទាំងស្ថាប័នពាក់ព័ន្ធទាំងឡាយ ដើម្បីរៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការឱ្យស្របតាមកម្រិតស្តង់ដារជាតិ និងអន្តរជាតិ។

**ទី២-ផ្នែកខាងក្នុងនៃមកុដ៖**

- ផ្ទៃពណ៌ស តំណាងឱ្យភាពបរិសុទ្ធ និងស្អាតស្អំក្នុងប្រព័ន្ធយុត្តាធិការតុលាការ
- នៅពីលើផ្ទៃពណ៌ស មានសរសេរអក្សរបែបបុរាណនាសម័យលង្វែក ដែលមានខ្លឹមសារថា៖ "**ត្រូវនៅក្នុងឱវាទច្បាប់ ចូលធ្វើឱយត្រង់ដៀវនៅបន្ទាត់ ត្រង់ណាហៅច្បាប់ កំណ្តាខ្ចាបកុំបីបង**" ខ្លឹមសារនេះបានបង្កប់នូវអត្ថន័យអប់រំបណ្តុះចិត្ត ដល់អ្នកដែលប្រកបវិជ្ជាជីវៈច្បាប់ និងតុលាការ ត្រូវធ្វើខ្លួនឱ្យស្ថិតនៅក្រោមឱវាទច្បាប់ រាល់ការវិនិច្ឆ័យសេចក្តី ត្រូវវៀរចាកអំពីអគតិធម៌ទាំង ៤ ប្រការគឺ៖ (ទី១).**ឆន្ទាគតិ** គឺសេចក្តីលម្អៀងព្រោះស្រឡាញ់, (ទី២).**ទោសាគតិ** គឺសេចក្តីលម្អៀងព្រោះស្អប់, (ទី៣).**មោហាគតិ** គឺសេចក្តីលម្អៀងព្រោះល្ងង់ និង(ទី៤).**ភយាគតិ** គឺសេចក្តីលម្អៀងព្រោះខ្លាចបុណ្យ ខ្លាចអំណាចគេ។ សម្រេចសេចក្តីប្រកបដោយយុត្តិធម៌មិនលម្អៀង, អនុវត្តតាមច្បាប់ឱ្យត្រង់ដូចបន្ទាត់ កុំបីបោះបង់វៀចវេរឡើយ។

**ទី៣-ផ្នែកកណ្តាល៖**

- មានអក្សរកាត់ "**ប.ភ.យ.ក.**" ដែលចារឹកលើសៀវភៅ សំដៅលើឈ្មោះពេញរបស់បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា តំណាងឱ្យគ្រឹះស្ថានបណ្តុះបណ្តាល មានបេសកកម្មរៀបចំការប្រឡងប្រជែងជ្រើសរើស និងរៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងដល់សិស្សចៅក្រម, សិស្សព្រះរាជអាជ្ញា, សិស្សក្រឡាបញ្ជី, សិស្សអាជ្ញាសាលា សិស្សសារការីដែលបានជ្រើសរើសថ្មី និងសិស្សវិជ្ជាជីវៈតុលាការ និងវិជ្ជាជីវៈច្បាប់ផ្សេងទៀត ព្រមទាំងទទួលបន្ទុកបណ្តុះបណ្តាលបន្ត ជូនដល់ចៅក្រម ព្រះរាជអាជ្ញា, ក្រឡាបញ្ជី, អាជ្ញាសាលា និងសារការីដែលកំពុងបំពេញការិយកម្ម
- សៀវភៅ តំណាងឱ្យបណ្តុំក្បួនច្បាប់ទាំងឡាយរបស់ជាតិ ដែលត្រូវបានយកមកបម្រើក្នុងវិស័យបណ្តុះបណ្តាលនៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

**ទី៤-ផ្នែកខាងក្រោម៖**

- មានជើងពានប្រកបដោយក្បូរក្បាច់រចនាយ៉ាងស់រវើក តំណាងឱ្យគ្រឹះដ៏រឹងមាំទ្រសៀវភៅបណ្តុំច្បាប់ទាំងឡាយ ដែលតួអង្គតុលាការ និងអ្នកវិជ្ជាជីវៈតុលាការ និងវិជ្ជាជីវៈច្បាប់ទាំងអស់ត្រូវតែចេះចាំស្ទាត់ជំនាញ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦២៣/៥៤០. ចុះថ្ងៃទី ២៥..... ខែ មិថុនា... ឆ្នាំ២០២៣
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាតុលាការយុត្តិធម៌កម្ពុជា

## អង្គការលេខនៃបណ្ឌិត្យសភាតុលាការយុត្តិធម៌កម្ពុជា

